クメール語

ជូនចំពោះអ្នកធ្វើការទាំងអស់គ្នា

# តើមានរឿងដែលពិបាកនៅកន្លែងធ្វើការដែររឺទេ？

**ការបៀតបៀននៅកន្លែងធ្វើការជាអំពើដែលមិនអាចលើកលែងឲ្យបាន។**

**សូមធ្វើការពិគ្រោះយោបល់ ប្រសិនបើអ្នកជួបនឹងបញ្ហាបែបនេះ។**

**មិនថាកម្មករជនជាតិជប៉ុន រឺ កម្មករជនជាតិបរទេស(ប្រភេទវីសា)ក៏ដោយ**

**ការបៀតបៀននៅកន្លែងធ្វើការ ※ ជាអំពើដែលមិនអាចលើកលែងឲ្យបាន។**

※កន្លែងធ្វើការក៏រួមបញ្ចូលដូចជា កន្លែងចុះបេសកកម្មការងារ នៅក្នុងរថយន្តដែលប្រើសម្រាប់បំពេញការងារ និងកន្លែងជួបជាមួយអតិថិជនផងដែរ។

ឧទាហរណ៍ សកម្មភាពបែបនេះត្រូវបានចាត់ទុកជា

## ការបៀតបៀន

**ការបំពានទៅលើរាងកាយ**

ត្រូវបានវាយដំ រឺ ទាត់ធាក់

**ការបំពានទៅលើផ្នែកស្មារតី**

បញ្ចេញកំហឹងនៅមុខបុគ្គលិកផ្សេងទៀតដោយនិយាយថា「ភាសាជប៉ុនងាយៗចឹងក៏មិនចេះដែរ！」

**ការទាមទារហួសកំណត់**

ការបង្ខំឲ្យធ្វើការងារដែលមិនមែនជាកាតព្វកិច្ច ដូចជាបង្ខំឲ្យធ្វើការបកប្រែភាសាបរទេស

**ការទាមទារដែលតិចជ្រុល**

មិនមានផ្តល់ការងារអ្វីឲ្យធ្វើ

**ការរំលោភបំពានលើបុគ្គល**

ការរិះគន់ពីស្ថានភាពវីរប្បធម៍របស់ប្រទេសកំណើត

**ការកាត់ផ្តាច់ទំនាក់ទំនង**

ត្រូវបានមិត្តរួមការងារ រឺ ថ្នាក់លើបន្តមិនអើពើជាមួយ

## ការបៀតបៀនផ្លូវភេទ

ត្រូវបានមេប៉ះចង្កេះរឺដើមទ្រូង
ហើយនៅពេលធ្វើការតវ៉ា ត្រូវបានផ្លាស់ប្តូរទៅផ្នែកការងារធ្វើផ្សេងទៀតដែលទទួលគុណវិបត្តិ

ត្រូវបានមេបង្ខំឲ្យទៅញ៉ាំអាហាររឺទៅដើរលេងជាមួយ
ហើយមានអារម្មណ៍ថាពិបាកទៅធ្វើការ

## ការបៀតបៀនក្នុងការឈប់សម្រាកពេលមានផ្ទៃពោះ សម្រាលកូន និងមើលថែកូនជាដើម

ពេលពិភាក្សាពីការឈប់សម្រាកមុនពេលសម្រាលកូនជាមួយថ្នាក់លើ ត្រូវបានថ្នាក់លើនិយាយថា「បើសិនជាសុំច្បាប់ឈប់សម្រាក នឹងបញ្ឈប់ការងារ」

ពេលពិភាក្សាពីការស្នើសុំមិនធ្វើការថែមម៉ោង ត្រូវបានថ្នាក់លើនិយាយថា「នឹងមិនធ្វើការតម្លើងឋានៈពេលធ្វើការវាយតម្លៃលើកក្រោយ」

**របៀបដោះស្រាយនិងកន្លែងទទួលពិគ្រោះយោបល់នៅពេលទទួលការបៀតបៀន សូមមើលផ្នែកខាងក្រោយ**

បន្ថែមពីលើនេះទៀត ・ ・ ・

ប្រសិនបើអ្នកត្រូវបានទទួលគុណវិបត្តិដោយសារសុំច្បាប់ឈប់សម្រាកពេលមានផ្ទៃពោះ សម្រាលកូន និងមើលថែកូនជាដើម
សូមពិនិត្យមើលខិត្តប័ណ្ណមួយផ្សេងទៀត

ひと、くらし、みらいのために 厚生労働省 Ministry of Health, Labour and Welfare

មន្ទីរការងារប្រចាំខេត្តក្រុង នាយកដ្ឋានគាំពារបរិស្ថាននិងសមភាពនៃការជួលបុគ្គលិក

# ប្រសិនបើទទួលបានការបៀតបៀន

## សូមប្រាប់ពីអារម្មណ៍របស់អ្នកឲ្យបានច្បាស់

ប្រសិនបើយើងនៅស្ងៀមមិននិយាយអ្វី
បញ្ហាអាចនឹងកាន់តែអាក្រក់ទៅៗ។
សូមនិយាយពីអារម្មណ៍ពិតរបស់អ្នកដូចជានិយាយថា
「សូមបញ្ឈប់」　「ខ្ញុំមិនចូលចិត្តទេ」

## សូមធ្វើការពិភាក្សាជាមួយនឹងផ្នែកពិគ្រោះនៅក្នុងក្រុមហ៊ុន

ការបៀតបៀនមិនមែនជាបញ្ហាបុគ្គលនោះទេ តែវាជាបញ្ហារបស់ក្រុមហ៊ុន។ សូមធ្វើការពិគ្រោះយោបល់ជាមួយអ្នកទទួលបន្ទុកផ្នែកពិគ្រោះរបស់ក្រុមហ៊ុនដូចជាផ្នែកធនធានមនុស្សនិងការងារជាដើម រឺទៅកាន់ថ្នាក់លើដែលអាចទុកចិត្តបាន។

**ប្រសិនបើពិបាកធ្វើការពិគ្រោះនៅក្នុងក្រុមហ៊ុន រឺ ទោះជាពិគ្រោះរួចហើយក៏មិនទទួលបានដំណោះស្រាយទេ សូមធ្វើការពិគ្រោះជាមួយទីភ្នាក់ងារខាងក្រៅដូចជាមន្ទីរការងារប្រចាំខេត្តក្រុង**

※ការទទួលគុណវិបត្តិដោយសារតែធ្វើការពិគ្រោះយោបល់ជារឿងដែលត្រូវបានហាមឃាត់

**ក្រុមហ៊ុនទាំងអស់មានកាតព្វកិច្ចរៀបចំវិធានការដូចខាងក្រោមដើម្បីការពារមិនឲ្យមានការបៀតបៀន !**

សម្រាប់ព័ត៍មានលម្អិត សូមមើលតាមលីងខាងក្រោម

1. ត្រូវបំភ្លឺពីគោលការណ៍របស់ម្ចាស់អាជីវកម្ម ឲ្យបានទូលំទូលាយ និង បង្រៀនឲ្យបានច្បាស់លាស់ទៅបុគ្គលិក
2. ត្រូវរៀបចំប្រព័ន្ធចាំបាច់ដើម្បីឆ្លើយតបឲ្យបានត្រឹមត្រូវនៅពេលមានការពិគ្រោះ (បូករួមទាំងពាក្យបណ្ដឹងផ្សេងៗ)
3. នៅពេលទទួលបានការពិគ្រោះយោបល់ ត្រូវធ្វើឆ្លើយតបឲ្យបានលឿន និង សមស្រប
4. ត្រូវមានវិធានការដើម្បីលុបបំបាត់មូលហេតុដែលបង្ករឲ្យមានការបៀតបៀន
5. (ការរក្សាភាពឯកជន) វិធានការដែលត្រូវអនុវត្តរួមគ្នា

■ ខិត្តប័ណ្ណ (ភាសាជប៉ុន) ※ចាប់ពីទំព័រទី២០ :
https://www.mhlw.go.jp/content/11900000/001019259.pdf

■ សមាគមន៍គាំទ្រកន្លែងការងារដែលមានភាពរីករាយ
https://www.no-harassment.mhlw.go.jp/foreign_workers_jp

**កន្លែងពិគ្រោះ (ឥតគិតថ្លៃ) : បញ្ជីលេខទូរស័ព្ទរបស់មន្ទីរការងារប្រចាំខេត្តក្រុង នាយកដ្ឋានគាំពារបរិស្ថាននិងសមភាពនៃការជួលបុគ្គលិក**

| ខេត្តក្រុង | លេខទូរស័ព្ទ | ខេត្តក្រុង | លេខទូរស័ព្ទ | ខេត្តក្រុង | លេខទូរស័ព្ទ | ខេត្តក្រុង | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|---|
| ហុកកៃដូ | 011-709-2715 | តូក្យូ | 03-3512-1611 | ស៊ីហ្គាក់ | 077-523-1190 | ខាហ្គាវ៉ា | 087-811-8924 |
| អាអូម៉ូរិ | 017-734-4211 | កាណាហ្គាវ៉ា | 045-211-7380 | ក្យូតូ | 075-241-3212 | អិហុិម៉េ | 089-935-5222 |
| អ៊ីវ៉ាតិ | 019-604-3010 | នីហ្គាតា | 025-288-3511 | អូសាកា | 06-6941-8940 | ខូឈិ | 088-885-6041 |
| មីយ៉ាហ្គិ | 022-299-8844 | តុយ៉ាម៉ា | 076-432-2740 | ហ្យូហ្គុ | 078-367-0820 | ហ្វឹគឹអូកាក់ | 092-411-4894 |
| អាគិតា | 018-862-6684 | អ៊ីសិហ្គាវ៉ា | 076-265-4429 | ណារ៉ា | 0742-32-0210 | សាហ្គាក់ | 0952-32-7218 |
| យ៉ាម៉ាហ្គាតា | 023-624-8228 | ហ្វឹគុយ | 0776-22-3947 | វ៉ាកាយ៉ាម៉ា | 073-488-1170 | ណាហ្គាសាគិ | 095-801-0050 |
| ហ្វឹគឹស៊ីម៉ា | 024-536-4609 | យ៉ាម៉ាណាស៊ិ | 055-225-2851 | តុតតុរិ | 0857-29-1709 |ឃើម៉ាម៉ូតុ | 096-352-3865 |
| អ៊ីបារ៉ាគិ | 029-277-8295 | ណាហ្គាណុ | 026-227-0125 | ស៊ីម៉ាណិ | 0852-31-1161 | អយតាក់ | 097-532-4025 |
| តិឈិហ្គិ | 028-633-2795 | ហ្គីហ្វឹ | 058-245-1550 | អូកាយ៉ាម៉ា | 086-225-2017 | មីយ៉ាសាគិ | 0985-38-8821 |
| ហ្គឹនម៉ា | 027-896-4739 | ស៊ីហ្សឺអូកា | 054-252-5310 | ហ៊ីរ៉ូស៊ីម៉ា | 082-221-9247 | ខាហ្គុស៊ីម៉ា | 099-223-8239 |
| សៃតាម៉ា | 048-600-6210 | អៃឈិ | 052-857-0312 | យ៉ាម៉ាហ្គុឈិ | 083-995-0390 | អូគិណាវ៉ា | 098-868-4380 |
| ឈិបាក់ | 043-221-2307 | មីអិ | 059-226-2318 | តុគឹស៊ីម៉ា | 088-652-2718 | | |

ម៉ោងធ្វើការ : ម៉ោង៨កន្លះព្រឹក～ម៉ោង៥:១៥នាទីល្ងាច (លើកលែងថ្ងៃសៅរ៍អាទិត្យ ថ្ងៃបុណ្យ ចុងឆ្នាំនិងដើមឆ្នាំ)

【ឯកសារយោង】 សេចក្ដីសង្ខេបនៃច្បាប់ស្ដីពីភាពស្មើគ្នានៃឱកាសការងាររបស់បុរសនិងស្ត្រី

ភាសាអង់គ្លេស　ភាសាចិន　ភាសាព័រទុយហ្គាល់　ភាសាវៀតណាម　ភាសាជប៉ុន